# លក្ខខណ្ឌទិញជាផ្នែកបន្ថែមចំពោះ BBSLA សម្រាប់ RIME STORES

## ១. វិសាលភាព និងការប្រើប្រាស់

១.១ កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណដំណោះស្រាយ BlackBerry (BlackBerry Solution License Agreement :BBSLA) អាចប្រើប្រាស់បានសម្រាប់រាល់ការចែកចាយ (ឥតគិតថ្លៃ និងគិតថ្លៃ) តាមរយៈ RIME Stores។ ផ្នែកបន្ថែមនេះសរសេរចូលនូវលក្ខខណ្ឌទិញបន្ថែមទៀត ("**លក្ខខណ្ឌទិញ**") ដែលអាចប្រើប្រាស់បានលើការទិញនៃការផ្តល់ឲ្យដែល RIME គឺជាពាណិជ្ជករគ្រប់គ្រង់លើកំណត់ត្រា (ឬភ្នាក់ងារសម្រាប់ពាណិជ្ជករនៃកំណត់ត្រា) សម្រាប់ការជួញដូរ (ដោយរួមចូលគ្នា "**ការទិញ**" និងសកម្មភាពក្នុងការទិញ "**ទិញ**" ឬ "**បានទិញ**"។ RIME មានន័យថា Research In Motion E-Commerce S.à.r.l, Research In Motion E-Commerce Corporation, Research In Motion E-Commerce Inc., ឬ សាខាក្រុមហ៊ុនរបស់ RIM ផ្សេងទៀតដែលបានកំណត់នៅគេហទំព័រ http://www.blackberry.com/legal/rime ថាជាអ្នកចែកចាយនៃការដាក់ស្នើរ ក្នុងយុត្តាធិការរបស់អ្នក។ ការយោងទៅកាន់ "**BlackBerry Commerce**" នៅក្នុង RIME Store ឬនៅក្នុងទំនាក់ទំនងដែលពាក់ព័ន្ធ ក្នុងគោលបំណងនៃលក្ខខណ្ឌទិញទាំងនេះ គឺជាការយោងទៅ កាន់ RIME។ លក្ខខណ្ឌពិសេសណាមួយនៅក្នុងផ្នែកបន្ថែមនេះ ដែលមិនបានកំណត់អត្ថន័យ អាចនឹងមានសរសេរអត្ថន័យនៅក្នុង BBSLA។ បើសិនជាអ្នកមិនទាន់មានច្បាប់ចម្លងរបស់ BBSLA សម្រាប់យុត្តាធិការរបស់អ្នកនៅឡើយទេ កិច្ចព្រមព្រៀងនេះអាចរកបាននៅគេហទំព័រ www.blackberry.com/legal ។

១.២ ផ្នែកបន្ថែមនេះក្លាយជាកិច្ចព្រមព្រៀងដែលត្រូវប្រតិបត្តិតាមរវាងអ្នក អ្នកទិញ (ដោយយោងចំពោះ "**អ្នក**" ឬ "**របស់អ្នក**" ដែលកំពុងត្រូវបានបកស្រាយជាលំដាប់លំដោយ) និង RIME នៅពេលដែលអ្នកឯកភាពនឹងផ្នែកបន្ថែមនេះដោយចុចលើ "ខ្ញុំយល់ព្រម" ខាងក្រោម ហើយនឹងប្រើបានលើរាល់ការទិញលើកក្រោយៗទៀត ប្រសិនបើមិន និងទាល់តែ RIME បញ្ជាក់ថាលក្ខខណ្ឌថ្មីដាក់ឲ្យប្រើសម្រាប់ការទិញលើកក្រោយ។ ប្រសិនបើអ្នកមិនបានត្រៀមខ្លួនរួចរាល់ដើម្បីឯកភាពលើផ្នែកបន្ថែមនេះ (ឬផ្នែកបន្ថែមនាពេលអនាគតផ្សេងទៀត ដោយយោងតាមការទិញ ដែលផ្នែកនោះត្រូវដាក់ឲ្យប្រើ) អ្នកមិនត្រូវបានអនុញ្ញាតឲ្យធ្វើការទិញឡើយ។ សូមបោះពុម្ពច្បាប់ចម្លងនៃលក្ខខណ្ឌទិញទាំងនេះ (ដែលអាចមើលបានតាម www.blackberry.com/legal) សម្រាប់ទុកជាឯកសាររបស់អ្នក។

១.៣ ដោយឯកភាពនឹងលក្ខខណ្ឌទិញទាំងនេះ អ្នកតំណាង និងធានាចំពោះ RIME ថាអ្នកមានអាយុលើសពីអាយុភាគច្រើនដែលស្ថិតក្រោមច្បាប់នៃយុត្តាធិការរបស់អ្នក។

១.៤ ការបញ្ជាទិញដែលធ្វើឡើងដោយអ្នក គឺជាការស្នើរបស់អ្នកទៅកាន់ RIME ដើម្បីទិញការផ្តល់ឲ្យមួយក្រោមលក្ខខណ្ឌរបស់ BBSLA ដូចបានកែប្រែដោយផ្នែកបន្ថែមនេះ និងត្រូវតែមានការទទួលពី RIME។ ការទទួលយកនៃកិច្ចសន្យាសម្រាប់ការទិញជាក់លាក់ណាមួយកើតឡើងមុនពេលនៃ (ក) RIME ទទួលបានការបង់ប្រាក់របស់អ្នកសម្រាប់ការទិញនោះ និង (ខ) RIME ផ្ញើការបញ្ជាក់ការបញ្ជាទិញទៅឲ្យអ្នក ដោយហេតុនោះក៏អនុញ្ញាតឲ្យអ្នកទាញយក ឬអាចចូលទៅកាន់ការផ្តល់ឲ្យបាន។ លក្ខខណ្ឌទិញ បង្កើតជាកិច្ចសន្យាដាច់ដោយឡែករវាងអ្នកនិង RIME សម្រាប់ការផ្តល់ឲ្យនីមួយៗ ហើយការខ្វះចន្លោះ ឬខ្វះខាតនៅក្នុងការផ្តល់ឲ្យណាមួយ នឹងមិនអនុញ្ញាតឲ្យអ្នកធ្វើការរំសាយការទិញរបស់អ្នកសម្រាប់ការទិញផ្សេងទៀតឡើយ ទោះបញ្ជាទិញក្នុងពេលតែមួយឬយ៉ាងណាក៏ដោយ។

១.៥ អ្នកទទួលស្គាល់ថា RIME កំពុងដើរតួនាទីជាភ្នាក់ងារនៃអ្នកលក់ការផ្តល់ឲ្យដើម្បីបំពេញការទិញ និងដោយលើកលែងផលិផលក្នុងកម្មវិធី គឺដើរតួនៅក្នុងការបំពេញការបញ្ជូននៃការផ្តល់ឲ្យទៅអ្នក។ ការបញ្ជូននៃការផ្តល់ឲ្យរបស់ RIME នឹងជាការអនុញ្ញាតឲ្យអ្នកធ្វើការទាញយក ឬបើកការផ្តល់ឲ្យពី កម្មវិធីលើឧបករណ៍ BlackBerry របស់អ្នក។ អ្នកទទួលស្គាល់បន្ថែមទៀតថា ផលិតផលក្នុងកម្មវិធី មិនបានរក្សាទុកនៅក្នុង Server របស់ RIME ឡើយ ហើយមិនត្រូវបានចែកចាយនៅក្នុង RIME Store ហើយវាគឺជាអ្នកលក់ការផ្តល់ឲ្យនៃផលិតផលក្នុងកម្មវិធីទាំងនោះ មិនមែនជារបស់ RIME នោះទេ ដែលត្រូវទទួលខុសត្រូវលើការបំពេញការបញ្ជូនផលិតផលក្នុងកម្មវិធីទៅឲ្យអ្នក។

១.៦ RIME នៅក្នុងការសម្រេចចិត្តរបស់ខ្លួនអាចបដិសេធការបញ្ជាទិញរបស់អ្នក (ដោយមិនបញ្ជាក់មូលហេតុ)។ បើសិនមានករណីនោះ គ្មានការបង់ប្រាក់ណាមួយនឹងត្រូវបានធ្វើឡើងឡើយ ឬកាត់ចេញពីវិធីចំណាយដែលមានការអនុញ្ញាតរបស់អ្នក ឬ RIME នឹងសងការបង់ប្រាក់ពីមុនណាមួយដែលបានបញ្ជាទិញលើការផ្តល់ឲ្យនោះ។

១.៧ អ្នកឯកភាព និងតំណាងថា អ្នកកំពុងទិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ និងមិនធ្វើការចែកចាយបន្តឡើយ។

១.៨ នៅក្នុងបរិបទនៃការទិញ សិទ្ធមានសរសេរនៅក្នុង BBSLA ដើម្បីធ្វើឲ្យទាន់សម័យ កែប្រែ និងកែតម្រូវទៅលើ RIME Store ដោយគ្មានការផ្តល់ដំណឹងជាមុន រួមមានការកែប្រែលើតម្លៃ និងលក្ខខណ្ឌទិញ ដោយរាប់ទាំងលក្ខខណ្ឌដែលពាក់ព័ន្ធនឹង RIME Store និងដំណោះស្រាយលើផលិតផលក្នុងកម្មវិធី ដោយប្រើប្រាស់សេវាកម្មបង់ប្រាក់របស់ BlackBerry ហើយការផ្លាស់ប្តូរទាំងនោះនឹងដាក់ឲ្យអនុវត្តតែសម្រាប់ការបញ្ជាទិញ ដែលមិនទាន់បានទទួលនៅក្នុងពេលនៃការផ្លាស់ប្តូរប៉ុណ្ណោះ។ គ្មានការការពារតម្លៃ ហើយបើសិនជាអ្នកជ្រើសរើសដើម្បីបន្តជាមួយការបញ្ជាទិញដែលមិនទាន់បានទទួលនៅពេលមានការផ្លាស់ប្តូរ អ្នកទទួលស្គាល់ថា ការផ្តល់ឲ្យនោះនឹងត្រូវផ្តល់ឲ្យដោយយោងទៅតាមការពិពណ៌នាដែលបានកែប្រែ ឬផ្លាស់ប្តូរ ឬតម្លៃកែតម្រូវ ហើយនឹងត្រូវធ្វើទៅតាមលក្ខខណ្ឌទិញដែលបានកែរួចនោះ។

១.៩ RIME អាចរក្សាកំណត់ត្រានៃឯកសារដែលពាក់ព័ន្ធរាល់ការជួញដូរទាំងសម្រាប់រយៈពេលណាមួយ ដូចបានអនុញ្ញាតដោយច្បាប់។ អ្នកគួរតែបោះពុម្ពច្បាប់ចម្លងនៃឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការទិញរបស់អ្នក តាមរយៈ RIME Store។ RIME អាច តែមិនអាចធានាថា RIME នឹងផ្តល់ច្បាប់ចម្លងទាំងអស់នោះទៅអ្នក ទៅតាមការស្នើសុំជាលាយល័ក្ខណ៍អក្សរនោះទេ។

## ២. សិទ្ធិ និងទំនួលខុសត្រូវ

២.១ RIME រក្សាសិទ្ធិក្នុងការបញ្ជាក់ពីទីតាំង និងព័ត៌មានចំណាយរបស់អ្នក (ដូចបញ្ជាក់ខាងក្រោម) និងធ្វើការពិនិត្យលើសុពលភាពនៃអត្តសញ្ញាណរបស់អ្នក ឬតាមដាននិងការពារប្រឆាំងការឆបោក ឬចោរ។

២.២ អ្នកមានទំនួលខុសត្រូវក្នុងការធ្វើឲ្យប្រាកដថាលេខសម្ងាត់ដែលអ្នកប្រើដើម្បីបើក ឬប្រើ RIME Store និង/ឬ សម្រាប់ធ្វើការចំណាយលើការផ្តល់ឲ្យ នៅតែមានសុវត្ថិភាព ហើយវិធាននៅក្នុង BBSLA ដែលពាក់ព័ន្ធនឹងលេខសម្ងាត់អាចអនុវត្តលើការប្រើប្រាស់របស់អ្នក ដើម្បីធ្វើការទិញ។ នៅពេលអ្នកបានបញ្ចូលលេខសម្ងាត់របស់ អ្នកនឹងមិនត្រូវការឲ្យបំពេញលេខសម្ងាត់ម្តងទៀតដើម្បីទិញ នៅក្នុងអំឡុងពេលមានសញ្ញាលេខសម្ងាត់បានបញ្ជាក់នៅក្នុងការកំណត់ជម្រើសចំណាយរបស់អ្នកនោះទេ។ បើសិនអ្នកចង់ឲ្យមានការរំលឹកលើការដាក់លេខសម្ងាត់សម្រាប់រាល់ការទិញ អ្នកត្រូវធ្វើការផ្លាស់ប្តូរលើការកំណត់លេខសម្ងាត់នៅក្នុងការកំណត់ជម្រើសការចំណាយរបស់អ្នក។

២.៣ ការផ្តល់ឲ្យដែលមាននៅក្នុង RIME Store ត្រូវបានផ្តោតសំខាន់សម្រាប់ឲ្យបុគ្គល ជាមួយនឹងសមត្ថភាពចាំបាច់ និងសមត្ថភាពដើម្បីឯកភាពស្របច្បាប់ចំពោះវិធាននៃព័ត៌មានចាំបាច់ និងដើម្បីចូលទៅកាន់កុងត្រាដែលត្រូវអនុវត្តតាម និងអនុវត្ត។ អ្នកយល់ព្រមទទួលខុសត្រូវលើហិរញ្ញវត្ថុដែលអ្នកប្រើនៅក្នុង RIME Store ព្រមទាំងការប្រើប្រាស់ណាមួយនៃគណនីរបស់អ្នក ឬព័ត៌មានបើកចូលដោយអ្នកដទៃ ដែលរាប់បញ្ចូលដូចជាគ្មានការកំណត់ តូចតាច ហើយអ្នកយល់ព្រមគ្រប់គ្រងរាល់ការប្រើប្រាស់ទាំងអស់នោះលើ RIME Store ហើយការទិញណាមួយក្រោមឈ្មោះ ឬគណនីរបស់អ្នក ដោយអ្នកប្រើប្រាស់ដែលមានការអនុញ្ញាតពីអ្នក។

២.៤ RIME រក្សាសិទ្ធិក្នុងការធ្វើសកម្មភាពដែល RIME ជឿថាចាំបាច់ ឬស័ក្តិសមដើម្បីអនុវត្ត និង/ឬ បញ្ជាក់ដោយអនុលោមតាមផ្នែកណាមួនៃលក្ខខណ្ឌទិញទាំងនេះ ដោយរាប់ទាំងការសម្របសម្រួលលើការផ្ទេរប្រាក់នៃពន្ធសមស្របសម្រាប់រដ្ឋាភិបាល ឬថ្លៃទៅឲ្យអ្នកលក់ការផ្តល់ឲ្យដែលអ្នកបានទិញ (បូកបញ្ចូលតែមិនកំណត់ទៅលើសិទ្ធិរបស់ RIME ដើម្បីសហការជាមួយសកម្មភាពស្របច្បាប់ណាមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់របស់អ្នកលើការផ្តល់ឲ្យ និង/ឬ ភាគីទីបីអះអាងថាការប្រើប្រាស់របស់អ្នកលើការផ្តល់ឲ្យមានលក្ខណៈមិនស្របច្បាប់ និង/ឬ រំលោភលើសិទ្ធិភាគីទីបីនោះ)។ អ្នកឯកភាពថា RIME មានសិទ្ធិ ដោយមិនទទួលខុសត្រូវចំពោះអ្នក ក្នុងការបង្ហាញព័ត៌មានណាមួយអំពីអ្នកទៅឲ្យអជ្ញាធរអនុវត្តិពន្ធ ឬច្បាប់ មន្ត្រីរដ្ឋាភិបាល និង/ឬ ភាគីទីបី នៅពេលដែល RIME ជឿថាចាំបាច់ ឬស័ក្តិសមដើម្បអនុវត្ត និង/ឬ បញ្ជាក់ដោយអនុលោមតាមផ្នែកណាមួយនៃលក្ខខណ្ឌទិញទាំងនេះ (បូកបញ្ចូលតែមិនកំណត់ទៅលើសិទ្ធិរបស់ RIME ក្នុងការសហការជាមួយសកម្មភាពស្របច្បាប់ណាមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់របស់អ្នកលើការផ្តល់ឲ្យ និង/ឬ ភាគីទីបីអះអាងថាការប្រើប្រាស់របស់អ្នកលើការផ្តល់ឲ្យមិនស្របច្បាប់ និង/ឬ រំលោភលើសិទ្ធិភាគីទីបីនោះ)។

## ៣. តម្លៃ ពន្ធ និង លក្ខខណ្ឌបង់ប្រាក់

៣.១ តម្លៃដែលអាចបង់សម្រាប់ការផ្តល់ឲ្យ គឺជាអ្វីដែលបានបង្ហាញនៅក្នុងផ្ទាំងបញ្ជាក់ការទិញនៅពេលទទួលបាន ហើយត្រូវដាក់សម្រាប់ពន្ធសមស្របដែលត្រូវបានកំណត់ដោយ RIME។ វិធីបង់ប្រាក់ដែលមានការអនុញ្ញាតរបស់អ្នក នឹងត្រូវបានគិតថ្លៃ និងបង់ពន្ធនៅពេលនៃការទទួលបានការបញ្ជាទិញរបស់អ្នក។ អ្នកជាអ្នកទទួលខុសត្រូវលើការចំណាយទឹកប្រាក់ទាំងនេះ។ ដើម្បីឲ្យច្បាស់ គឺគ្មានការសងប្រាក់វិញឡើង បើសិនជាតម្លៃធ្លាក់ចុះបន្ទាប់ពីការទិញរបស់អ្នក ឬបើសិនជាមានការផ្តល់ជូនពិសេសនៅពេលក្រោយទៅលើការផ្តល់ឲ្យដែលអ្នកបានទិញនោះទេ។ ប្រសិនបើអ្នកមានអារម្មណ៍ថាវិធីសាស្ត្របង់ប្រាក់ដែលមានការអនុញ្ញាតរបស់អ្នក ត្រូវបានដាក់ ឬគិតខុស អ្នកត្រូវផ្តល់ដំណឹងដល់ សេវាអតិថិជនរបស់ RIME Store ក្នុងរយៈពេល ៣០ ថ្ងៃនៃការទិញរបស់អ្នក តាមរយៈគេហទំព័រ https://www.blackberry.com/technicalsupport/index.do?ft=generic ។

៣.២ ការផ្តល់ឲ្យមួយចំនួន គឺអាចមានលើមូលដ្ឋានចុះឈ្មោះជាថ្មីដោយស្វ័យប្រវត្តិ ដែលនេះអាចសន្សំសំចៃពេលវេលា ការប្រឹងប្រែង និងហានិភ័យរបស់អ្នក ដោយពង្រីកការចុះឈ្មោះរបស់អ្នកដោយស្វ័យប្រវត្តិមុនពេលវាហួសកំណត់។ ដោយទិញការផ្តល់ឲ្យដែលមានការចុះឈ្មោះជាថ្មីដោយស្វ័យប្រវត្តិ អ្នកឯកភាពថាការចុះឈ្មោះរបស់អ្នក អាចធ្វើជាថ្មីដោយស្វ័យប្រវត្តិសម្រាប់លក្ខខណ្ឌធ្វើឲ្យថ្មីតគ្នា ហើយអ្នកអនុញ្ញាត និងយល់ព្រមឲ្យ RIME គិតថ្លៃលើថ្លៃចុះឈ្មោះជាថ្មីនីមួយៗ ទៅលើវិធីសាស្ត្របង់ប្រាក់ដែលអ្នកបានជ្រើសរើសរហូតដល់ពេលដែលអ្នក( ឬសម្រាប់ការចុះឈ្មោះជារង្វាន់ អ្នកឬអ្នកទទួលរង្វាន់) លុបចោលការចុះឈ្មោះនោះ ឬ RIME បញ្ឈប់ការធ្វើឲ្យថ្មីដោយស្វ័យប្រវត្តិ និងបញ្ឈប់ការគិតថ្លៃលើការចុះឈ្មោះនោះ។ សម្រាប់ការផ្តល់ឲ្យដែលមានការចុះឈ្មោះដោយស្វ័យប្រវត្តិនីមួយៗ ដែលអ្នកទិញ អ្នកនឹងទទួលបានអ៊ីមែលយ៉ាងតិចមួយនៅក្នុងអាសយដ្ឋានអ៊ីមែលរបស់អ្នក ដែលបានផ្តល់ឲ្យនិងភ្ជាប់ជាមួយ BlackBerry ID ដើម្បីរំលឹកអ្នកពីការជិតមកដល់នៃការចុះឈ្មោះជាថ្មី មុនពេលការចុះឈ្មោះជាថ្មីរបស់អ្នកត្រូវបានធ្វើឡើង។ អ្នកមានសិទ្ធិគ្រប់គ្រងពេញលេញលើការចុះឈ្មោះរបស់អ្នក ហើយអាចលុបចោលការចុះឈ្មោះដោយស្វ័យប្រវត្តិនោះបានគ្រប់ពេលវេលា។ ការបញ្ជាក់ពីការបញ្ជាទិញ និងអ៊ីមែលបញ្ជាក់របស់អ្នក នឹងមានដាក់ពីការណែនាំលើរបៀបលុបការធ្វើឲ្យថ្មីដោយស្វ័យប្រវត្តិ របស់អ្នក។ សូមកត់ចំណាំថា បើសិនអ្នកបញ្ឈប់ការចុះឈ្មោះរបស់អ្នកសម្រាប់ការផ្តល់ឲ្យជាក់លាក់ណាមួយ។ អ្នកត្រូវធ្វើឲ្យថ្មីដោយខ្លួនឯង ដើម្បីបង្កាការបង្អាក់លើការប្រើប្រាស់ការផ្តល់ឲ្យនោះ។

៣.៣ ការគិតថ្លៃទាំងអស់សម្រាប់ការទិញ នឹងត្រូវបានធ្វើឡើងតាមវិធីសាស្ត្របង់ប្រាក់ដែលអ្នកបានជ្រើសរើសនៅក្នុង RIME Store ណាមួយ។ បើសិនអ្នកចង់ធ្វើការផ្លាស់ប្តូរវិធីសាស្ត្របង់ប្រាក់របស់អ្នក អ្នកអាចធ្វើបានដោយចូលទៅកាន់មីនុយជម្រើសការបង់ប្រាក់នៅក្នុង RIME Store។

## ៤. លក្ខខណ្ឌអាជ្ញាប័ណ្ណអ្នកលក់

៤.១ ជាមួយការចែកចាយដោយសេរីនៅក្នុង RIME Store ចំណងជើងមិនអនុញ្ញាតជាមួយការទិញនៃឯកសារ និងការផ្តល់ឲ្យកម្មវិធីឡើង។ អ្នកមានសិទ្ធក្នុងការប្រើប្រាស់ច្បាប់ចម្លងរបស់ឯកសារ និងការផ្តល់ឲ្យកម្មវិធី ដែលអ្នកទិញ និងដោយយោងតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណអ្នកប្រើប្រាស់ ច្បាប់ ឬលក្ខខណ្ឌផ្សេងទៀត ដែលត្រូវបានបញ្ចូលជាមួយការផ្តល់ឲ្យ ("**លក្ខខណ្ឌអាជ្ញាប័ណ្ណអ្នកលក់**")។ BBSLA មានរៀបរាប់ពីលក្ខខណ្ឌដែលអនុវត្តនៅពេលដែលគ្មានលក្ខខណ្ឌអាជ្ញាប័ណ្ណអ្នកទិញ។ លក្ខខណ្ឌអាជ្ញាប័ណ្ណមួយចំនួន អាចត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់សម្រាប់សេវាកម្មសំខាន់មួយ។ ឧទាហរណ៍ ប្រសិនបើអ្នកទិញ ការជួលលើភាពយន្តមយយ នោះនឹងមានការកំណត់លើពេលវេលាដែលពាក់ព័ន្ធនឹងពេលដែលអាចត្រូវតែចាប់ផ្តើមមើលភាពយន្ត (ឧទាហរ៍ណ ក្នុងរយៈពេល ៣០ ថ្ងៃនៃការទិញ) ហើយនៅពេលអ្នកចាប់ផ្តើមមើលភាពយន្ត នោះនឹងមានការកំណត់លើពេលណាដែលអ្នកត្រូវតែបញ្ចប់ការមើលនោះ (ឧទាហរណ៍ ក្នុងរយៈពេល ២៤ ម៉ោង)។ ក៏នឹងប្រហែលជាមានការកំណត់លើម៉ូតនៃឧបករណ៍ផងដែរ ឬលើឧបករណ៍ប៉ុន្មានប្រភេទដែលអ្នកអាចមើលភាពយន្តបាន។ អ្នកទទួលស្គាល់ និងឯកភាពថាសមត្ថភាពរបស់អ្នកក្នុងការបើក ឬប្រើប្រាស់ការផ្តល់ឲ្យទាំងនោះ អាចបញ្ចប់ដោយស្វ័យប្រវត្តិ ដោយគ្មានការផ្តល់ដំណឹងលើកក្រោយទៅអ្នក ដោយយោងតាមលក្ខខណ្ឌអាជ្ញាប័ណ្ណដែលអាចប្រើបាន។

## ៥. ហានិភ័យ និងការថតទុក

៥.១ លើកលែងអ្វីដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌទិញ ហានិភ័យនៃការបាត់បង់ ឬខូចខាតចំពោះការផ្ដល់ឲ្យក្នុង RIME Store និងផលិតផលក្នុងកម្មវិធី (In-App Product) អនុញ្ញាតឲ្យអ្នកពី RIME និងអ្នកលក់ការផ្ដល់ឲ្យនោះតាមរយៈការទាញយក។ ជាមួយការចែកចាយផ្សេងទៀតនៃការផ្ដល់ឲ្យ នៅពេលដែលអ្នកទាញយកការផ្ដល់ឲ្យណាមួយ វានឹងក្លាយជាទំនួលខុសត្រូវរបស់អ្នក ហើយ RIME ឬសាខាក្រុមហ៊ុន ឬអ្នកលក់ការផ្ដល់ឲ្យនោះ នឹងមិនទទួលខុសត្រូវលើការបាត់បង់ ការបំផ្លាញ ឬខូចខាត ចំពោះឯកសារតាំងនោះឡើយ។ អ្នកគួរតែថតទុកការផ្ដល់ឲ្យរបស់អ្នក។ កន្លែងដាក់ទុកក្នុង RIME Store របស់អ្នក ("**ពិភពរបស់ខ្ញុំ**" (**My World**)) អាចឲ្យអ្នកលុបចេញ និងដំឡើងជាថ្មីនូវកម្មវិធី និងឯកសារភាគីទីបីជាក់លាក់ណាមួយ នៅលើផលិតផលឧបករណ៍របស់អ្នក ដូចមានបញ្ជាក់លម្អិតនៅក្នុងគោលការណ៍សម្រាប់ My World ដែលអាចកែប្រែជាបន្តបន្ទាប់។

## ៦. គោលនយោបាយសងប្រាក់វិញ ការគាំទ្ររបស់ RIME សម្រាប់ RIME Store និងការគាំទ្រសម្រាប់ផលិតផល

៦.១ គ្រប់ការទិញទាំងអស់ ត្រូវបានដាក់ចូលនៅ ក្នុងគោលនយោបាយសងប្រាក់វិញរបស់ RIME ដែលអាចរកបាននៅ http://www.blackberry.com/legal/rime-store-refunds-policy ដោយមានការធ្វើឲ្យទាន់សម័យជាបន្តបន្ទាប់។

៦.២ សូមចូលទៅកាន់គេហទំព័រគាំទ្រសម្រាប់ RIME Store ដែលត្រូវបានអនុវត្តន៍សម្រាប់សេវាកម្មគាំទ្រ ដែលមានសម្រាប់ RIME Store និងសម្រាប់បញ្ហាទាញយក។ អ្នកលក់ការផ្ដល់ឲ្យ មានទំនួលខុសត្រូវលើការធានា និងគាំទ្រសម្រាប់ការផ្ដល់ឲ្យរបស់ពួកគេ។

៦.៣ វិធាននៃកិច្ចព្រមព្រៀង BBSLA ដែលទាក់ទិននឹងការផ្ដល់ឲ្យណាមួយ ដោយរាប់បញ្ចូលទាំងការផ្ដល់ឲ្យដែលពាក់ព័ន្ធនឹងប្រភេទមួយនៃការផ្ដល់ឲ្យ ដូចជាកម្មវិធី សេវាកម្ម RIM ឯកសារភាគីទីបី និងសេវាកម្មភាគីទីបី ត្រូវអនុវត្តន៍លើការទិញរបស់អ្នកលើការផ្ដល់ឲ្យ។ ដោយគ្មានការកំណត់លើការផ្ដល់ឲ្យខាងដើម អាជ្ញាប័ណ្ណ ភាពឯកជន ការនាំចេញ ការធានា ការបដិសេធ ការមិនរាប់បញ្ចូល និងការកំណត់នៃការទទួលខុសត្រូវ មានសរសេរនៅក្នុងកិច្ចព្រមព្រៀង BBSLA ដែលអនុវត្តន៍លើកម្មវិធី សេវាកម្ម RIM ឯកសារភាគីទីបី និងសេវាកម្មភាគីទីបី ដែលអនុវត្តន៍លើការទិញរបស់អ្នកលើការផ្ដល់ឲ្យ ដែលជាកម្មវិធី សេវាកម្ម RIM ឯកសារភាគីទីបី និងសេវាកម្មភាគីទីបី។ នៅកម្រិតអតិបរមាដែលត្រូវបានអនុញ្ញាតដោយច្បាប់អនុវត្តន៍ ការកំណត់ ការមិនរាប់បញ្ចូល និងការបដិសេធនៅក្នុងកិច្ចព្រមព្រៀង នឹងដាក់អនុវត្តន៍ចំពោះអ្នកផ្គត់ផ្គង់សេវាកម្មរបស់ RIME (ដោយរាប់បញ្ចូល ដោយគ្មានការកំណត់ អ្នកផ្គត់ផ្គង់នៃសេវាកម្មដែលពាក់ព័ន្ធនឹងប្រតិបត្តិការបង់ប្រាក់។

## ៧. ការព្រមព្រៀង និងកាតព្វកិច្ចពន្ធគយ

៧.១ អ្នកអាចនឹងត្រូវដាក់ឲ្យ និងទទួលខុសត្រូវលើការបង់ពន្ធគយ និង/ឬ កាតព្វកិច្ចនាំចូលដែលត្រូវបានដកពន្ធ នៅពេលដែលអ្នកទាញយកការផ្ដល់ឲ្យ។ ការគិតថ្លៃបន្ថែមផ្សេងទៀតសម្រាប់ពន្ធដារ ឬកាតព្វកិច្ចនាំចូល ត្រូវតែបង់ប្រាក់

ដោយអ្នកផ្ទាល់។ អ្នកគួរតែទាក់ទងការិយាល័យពន្ធគយក្នុងស្រុក ក្រោមយុត្តាធិការពាក់ព័ន្ធ សម្រាប់ព័ត៌មានបន្ថែមលើគោលនយោបាយ ឬកាតព្វកិច្ចពន្ធគយ។

៧.២ អ្នកអាចទទួលអាជ្ញាប័ណ្ណ ឬការអនុញ្ញាតដែលចំណាយដោយអ្នកផ្ទាល់ ពីរដ្ឋាភិបាល ឬអាជ្ញាធរណាមួយដែលចាំបាច់សម្រាប់ទទួល ឬប្រើប្រាស់ការផ្ដល់ឲ្យដោយអ្នក ហើយបើចាំបាច់ បង្កើតជាភស្តុតាងទៅឲ្យ RIME តាមសេចក្ដីត្រូវការ។ បរាជ័យមិនអាចធ្វើបែបនេះបាន នឹងមិនអនុញ្ញាតឲ្យអ្នករក្សាទុក ឬពន្យាការបង់ប្រាក់សម្រាប់ការផ្ដល់ឲ្យនោះឡើយ។ ការចំណាយបន្ថែមណាមួយ ឬការគិតថ្លៃណាមួយដែលធ្វើឡើងដោយ RIME ដោយសារអ្នកមិនអាចធ្វើបានដូចផ្នែកនេះ នឹងត្រូវបង់ដោយអ្នក។ ការផ្ដល់ឲ្យអាចត្រូវនាំចេញ នាំចូល និងប្រើប្រាស់ច្បាប់ និងបទបញ្ជាច្បាប់ នៅក្នុងទឹកដី ឬយុត្តាធិការពាក់ព័ន្ធផ្សេងទៀត នៅកន្លែងដែលអ្នកយកការចែកចាយ នាំចេញការផ្ដល់ឲ្យពី នាំចូលការផ្ដល់ឲ្យទៅ ឬប្រើប្រាស់ការផ្ដល់ឲ្យ។ អ្នកមានទំនួលខុសត្រូវលើការអនុលោមតាមច្បាប់ និងបទបញ្ជាទាំងនោះ និងតំណាង និងធានាថា អ្នកនឹងមិនធ្វើអ្វីរំលោភលើច្បាប់ទាំងនោះឡើយ។ អ្នកយល់ព្រមទៀតថា អ្នកនឹងត្រូវសងការខូចខាតពេញលេញដល់ RIME និងអ្នកផ្គត់ផ្គង់សេវាកម្មណាមួយរបស់ RIME សម្រាប់បរាជ័យរបស់អ្នកក្នុងការអនុលោមតាមផ្នែកនេះ។

## ៨. ព័ត៌មានផ្ទាល់ខ្លួន និងភាពឯកជនរបស់អ្នក

៨.១ បន្ថែមលើព័ត៌មានដែលអ្នកបានឯកភាព ក្រោមកិច្ចព្រមព្រៀង BBSLA ថា RIME អាចធ្វើប្រតិបត្តិការដើម្បីបំពេញ និងបញ្ចូញការទិញរបស់អ្នក RIME អាចធ្វើប្រតិបត្តិការគណនីវិធីសាស្ត្រដែលមានការអនុញ្ញាតរបស់អ្នក និងព័ត៌មានលម្អិតផ្សេងទៀត ដូចជាលេខកាតក្រេឌីត អាសយដ្ឋានគិតថ្លៃ ព័ត៌មានអ្នកផ្គត់ផ្គង់សេវាកម្មអ៊ែថាម ព័ត៌មានអំពីការផ្ដល់ឲ្យដែលបានទាញយក និងទិញ និងព័ត៌មានកំណត់ឧបករណ៍ និងព័ត៌មានអ្នកប្រើប្រាស់ផ្សេងទៀត ដូចជាទីតាំងរបស់អ្នកនៅពេលទិញ ("**ព័ត៌មានបង់ប្រាក់**")។ អ្នកឯកភាពថា RIME អាចទទួលបានព័ត៌មានទាំងនោះដោយផ្ទាល់ ឬពីអ្នកផ្គត់ផ្គង់សេវាកម្ម ដែលផ្ដល់ការដឹកជញ្ជូន និងសេវាកម្មបំពេញទៅឲ្យ RIME អ្នកប្រតិបត្តិការបង់ប្រាក់មានដូចជា PayPal ក្រុមហ៊ុនកាតក្រេឌីត ឬ នៅក្នុងករណីគិតប្រាក់តាមក្រុមហ៊ុនទូរស័ព្ទ ដែលលក្ខខណ្ឌទិញទាំងនេះអនុវត្តន៍អ្នកផ្គត់ផ្គង់សេវាកម្មអ៊ែថថាម តាមដែលអាចអនុវត្តបាន។ អ្នកយល់ព្រមឲ្យ RIME ផ្ដល់ព័ត៌មានបង់ប្រាក់របស់អ្នកទៅឲ្យភាគីទីបី MoR អ្នកប្រតិបត្តិការការបង់ប្រាក់ ឬអង្គភាពផ្សេងទៀត ដែលចាំបាច់ដើម្បីសម្របសម្រួលការទិញ និងសេវាកម្មបម្រើ។ នៅក្នុងករណីខ្លះនៅពេលដែលអ្នកបានផ្ដល់ភាគីទីបី MoR ពីមុន ជាមួយព័ត៌មានកាតក្រេឌីតរបស់អ្នក អ្នកអាចត្រូវបានសួរបើសិនជាភាគីទីបីនោះផ្ដល់ព័ត៌មាននេះមកឲ្យ RIME ដើម្បីប្រើប្រាស់ នៅពេលដែល RIME ដើរតួជា MoR សម្រាប់ការទិញរបស់អ្នក។ បើសិន RIME ទទួលបានព័ត៌មានបង់ប្រាក់បែបនោះ វានឹងត្រូវបានប្រើប្រាស់ទៅតាមការចាំបាច់ដើម្បីសម្របសម្រួលការទិញរបស់អ្នក ដោយយោងតាមលក្ខខណ្ឌទិញទាំងនេះ។

៨.២ ព័ត៌មានផ្ទាល់ខ្លួនដែលត្រូវបានធ្វើប្រតិបត្តិការដោយ RIME និងសាខាក្រុមហ៊ុន និងអ្នកផ្គត់ផ្គង់សេវាកម្ម នឹងត្រូវបានធ្វើឡើងដោយយោងតាមគោលនយោបាយភាពឯកជនរបស់ RIM (ដែលត្រូវបានបញ្ចូលនៅទីនេះដោយ

សេចក្តីបញ្ជាក់ និងអាចមើលបាននៅ www.blackberry.com/legal ឬអាចទទួលបានតាមអ៊ីមែល legalinfo@rim.com)។ ប្រតិបត្តិការនោះអាចរួមបញ្ចូលសេវាកម្មបញ្ជូនទៅឲ្យ និងសេវាកម្មបំពេញបម្រើ ដែលពាក់ព័ន្ធនឹងការទិញរបស់អ្នក ដូចជាដើម្បីបញ្ជូនការបញ្ជាទិញរបស់អ្នក ទទួលការបង់ប្រាក់ ផ្តល់ដំណឹងដល់អ្នកពីស្ថានភាពនៃការបញ្ជាទិញរបស់អ្នក សម្របសម្រួលការធ្វើឲ្យទាន់សម័យ ឬការធ្វើឲ្យថ្មីឡើងវិញនៃការចុះឈ្មោះសម្រាប់ការផ្តល់ឲ្យ (បើសិនជាមាន) កែលម្អ RIME Store និងផ្តល់ឲ្យអ្នកនូវសេវាកម្មអតិថិជនដ៏មានប្រសិទ្ធិភាព អនុវត្តការកំណត់ការផ្តល់អាជ្ញាប័ណ្ណ ផ្ទេរពន្ធអាករដែលអាចអនុវត្ត បញ្ជាក់អត្តសញ្ញាណ និងពិនិត្យក្រេឌីត ស៊ើបអង្កេត និងការពារសកម្មភាពឆបោក និងអនុលោមតាមសេចក្តីត្រូវការផ្លូវច្បាប់ និងបទបញ្ជា ឬដូចបានអនុញ្ញាតដោយច្បាប់។ ព័ត៌មានបង់ប្រាក់អាចត្រូវបានប្រតិបត្តិការដោយ ឬក្នុងនាមរបស់ RIME នៅខាងក្នុង ឬខាងក្រៅប្រទេសដែលអ្នកតាំងទីលំនៅ ដែលរាប់បញ្ចូលដោយមិនកំណត់ដូចជានៅក្នុង ប្រទេសកាណាដា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សិង្ហបុរី ឬប្រទេសផ្សេងទៀតដែលមានបរិក្ខាប្រតិបត្តិដោយ ឬក្នុងនាមក្រុមហ៊ុនរបស់ RIM Group ឬអ្នកផ្គត់ផ្គង់សេវាកម្មដែលអាចអនុវត្តបាន។ បើសិនអ្នកជាប្រជាជននៃតំបន់សេដ្ឋកិច្ចអឺរ៉ុប ឬប្រទេសណាមួយដែលត្រូវការការអនុញ្ញាតដើម្បីផ្ទេរព័ត៌មានផ្ទាល់ខ្លួនក្រៅពីយុត្តាធិការនោះ អ្នកយល់ព្រមចំពោះប្រតិបត្តិការនោះ។

## ៩. ព័ត៌មានបន្ថែម

៩.១ ព័ត៌មានទំនាក់ទំនង និងព័ត៌មានបន្ថែមសម្រាប់ RIME អាចរកបាននៅ http://blackberry.com/legal/rime ។